ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ

# សៀវភៅស្តីពីការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ







ឆ្នាំ ២០១៧

សៀវភៅនេះរៀបរៀង និងបោះពុម្ពដោយនាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។

រក្សាសិទ្ធដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វរាល់ការផលិតឡើងវិញនៃផ្នែកខ្លះ ឬទាំងស្រុងសៀវភៅនេះត្រូវបានការអនិញ្ញាតិពីអ្នកបោះពុម្ពជាមុនជាលាយលក្ខអក្សរ។

**អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ**

អាសយដ្ឋាន: ផ្លូវលេខ៣៧១ ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌស្ទឹងមានជ័យ រាជធានីភ្នំពេញ
លេខទូរសព្ទ : ០២៣ ៨៨៤ ៣៤៥ / ០១២ ៩៨២ ៩២៧

# មាតិកាអត្ថបទ

ទំព័រ

**ជំពូក១** សេចក្តីផ្តើម................................................................................................ ១

**ជំពូក២** ការចាប់ផ្តើមចិញ្ចឹម-ការជ្រើសមាន់................................................................. ២

**ជំពូក៣** ប្រភេទមាន់និងការអនុវត្តន៍ការបង្កាត់ពូជ.......................................................៥

**ជំពូក៤** ការសង់ទ្រុងនិងសំភារៈបរិក្ខា..........................................................................៨

**ជំពូក៥** ការគ្រប់គ្រង................................................................................................ ១៩

**ជំពូក៦** ចំណីអាហារ.................................................................................................៣៥

**ជំពូក៧** កម្មវិធីសុខភាពសត្វស្លាប...............................................................................៥៤

**ជំពូក៨** ការលក់ដូរ.................................................................................................. ៦៩

**ជំពូក៩** ការណែនាំសំខាន់ៗដើម្បីឲ្យការចិញ្ចឹមមាន់សាច់ទទួលបានជោគជ័យ.................................. ៧១

**ជំពូក១០** ការណែនាំសំខាន់ៗដើម្បីឲ្យផលិតកម្មស៊ុតទទួលបានជោគជ័យ.....................................៧២

ម.ឯ.ឯ.ក AIDOC
Code: 231-026
Date:
Donated by:

# អារម្ភកថា

សៀវភៅ "ការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ" ត្រូវបានចងក្រងឡើងដោយផ្អែកលើបទពិសោធន៍ជាក់ស្តែង សៀវភៅដែលមានស្រាប់ និងឯកសារបច្ចេកទេសពីបណ្តាប្រទេសផ្សេងៗស្តីពីការចិញ្ចឹមមាន់ដែលគេបានអនុវត្តកន្លងមក។ ដើម្បីជាជំនួយបន្ថែមដល់អ្នកអាន ងាយយល់ និងចាប់អារម្មណ៍ ក្រុមការងារបានបញ្ចូលនូវរូបភាពថ្មីក្នុងពេលអនុវត្តការងារ និងប្រើពាក្យបច្ចេកទេសសាមញ្ញៗដែលជម្រុញឲ្យអ្នកអានគ្រប់មជ្ឈដ្ឋានងាយស្រួលយល់ និងអាចយកទៅអនុវត្តបាន។

ឯកសារនេះមានគោលបំណងជួយជម្រុញផលិតកម្មមាន់ដែលស្របទៅនឹងផែនការយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ២០១៦-២០២៥ ក្នុងការលើកកំពស់វិស័យសុខភាពសត្វ និងផលិតកម្មសត្វ ដែលអាចជួយជម្រុញកំណើនសេដ្ឋកិច្ចជាតិក្នុងនោះគឺការលើកកំពស់សន្តិសុខស្បៀងសុវត្ថិភាពចំណីអាហារ និងអនុផលផ្សេងៗទៀតសម្រាប់តម្រូវការរបស់មនុស្ស ដែលកំពុងមានកើនពីមួយឆ្នាំ ទៅមួយឆ្នាំ ជាពិសេសការលើកកំពស់កំណើនជីវភាពគ្រួសារអ្នកចិញ្ចឹមសត្វនៅតាមជនបទ។

ខ្ញុំសូមកោតសរសើរដោយស្មោះចំពោះស្នាដៃរៀបចំនិពន្ធសៀវភៅនេះឡើងដោយលោក**គា ផា** អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម។ ខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកពាក់ព័ន្ធទាំងអស់ក្នុងការចូលរួមផ្តល់គំនិតផ្តួចផ្តើម និងកែសម្រួលដល់ការរៀបចំតាក់តែងសៀវភៅបច្ចេកទេសស្តីពីការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារដែលរួមមាន៖ លោកស្រីបណ្ឌិត **អុក សាវិន** អគ្គនាយករងនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ, លោក**លឿង វ៉ាន់អៀង** អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម, លោក**ថោង សំណាង** អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម, លោកស្រី**ហុក ច័ន្ទផល្លាត** ប្រធានការិយាល័យផ្សព្វផ្សាយបច្ចេកទេស, លោក**ឃួន ម៉េងឡុង** អនុប្រធានការិយាល័យផ្សព្វផ្សាយបច្ចេកទេស និងលោក**ព្រាប ប្រាជ្ញា** អនុប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍ ដែលបានចំណាយពេលវេលាដ៏មានតម្លៃដើម្បីចូលរួមកែលម្អធ្វើឱ្យសៀវភៅនេះលេចចេញជារូបរាងឡើងនាពេលថ្មីៗនេះ នៅកម្ពុជា។ យើងជឿជាក់ថា សៀវភៅនេះនឹងក្លាយជាមូលដ្ឋានគ្រឹះមួយសម្រាប់អ្នកចិញ្ចឹម សិស្ស និស្សិតដើម្បីអភិវឌ្ឍន៍ចំណេះដឹងរបស់ខ្លួន ក៏ដូចជាជួយបំពេញកង្វះខាត នៃការចិញ្ចឹមមាន់ជាពិសេសលើការគ្រប់គ្រងផលិតកម្មមាន់ ដែលអាចធ្វើឲ្យអាជីវកម្មលើការចិញ្ចឹមមាន់របស់អស់លោក-លោកស្រី ជាពិសេសប្រជាកសិករក្លាយជាមុខរបរដ៏ពិតប្រាកដមួយដើម្បីស្វែងរកប្រាក់ចំណូលសម្រាប់ជីវភាពគ្រួសារ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**

**អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ**

**សេន សុវណ្ណ**

# ជំពូកទី១

## សេចក្តីផ្តើម ( Introduction )

មនុស្សភាគច្រើនចូលចិត្តចិញ្ចឹមសត្វស្លាបជាងសត្វដទៃទៀត ។ គេអាចផ្តើមពីការចិញ្ចឹមសត្វដើម្បីដោះស្រាយម្ហូបអាហារផ្ទាល់ខ្លួន និងដើម្បីលក់យកថវិកាសម្រាប់ដោះស្រាយពេលមានពិធីបុណ្យទាន ពិធីរៀបមង្គលការ និងពិធីផ្សេងៗទៀត។ សៀវភៅនេះអាចចាត់ទុកថាជាវិធីសាស្ត្រសំខាន់ទី១ ក្នុងការចិញ្ចឹមសត្វស្លាបឲ្យមានសុខភាពល្អ។ គេបានលើកឡើងជាយោបល់ផ្សេងៗស្តីអំពីរបៀបពង្រីកកសិដ្ឋានចិញ្ចឹមសត្វស្លាបក្នុងជំហានដំបូងតាមទ្រង់ទ្រាយតូច។

ដោយសារមាន់ជាបក្សីស្រុកមួយប្រភេទដែលគេចូលចិត្តចិញ្ចឹមច្រើនបំផុតនៅលើកសិដ្ឋានភូមិ និងទីក្រុងផងដែរគេបានរៀបចំចងក្រងសៀវភៅស្តីអំពីការគ្រប់គ្រងការចិញ្ចឹមមាន់ដែលអាចអនុវត្តន៍បានផងដែរ ចំពោះការចិញ្ចឹមបក្សីដទៃៗទៀតដូចជាៈ ទា ក្ងាន មាន់ទោ មាន់ជាំងជុង ក្រួច និងព្រាប និងសត្វកំដរអារម្មណ៍ផ្សេងៗទៀត។

អ្នកចិញ្ចឹមសត្វស្លាបជាច្រើនបានចាប់ផ្តើមចិញ្ចឹមសត្វស្លាបបន្តិចបន្តួចគ្រាន់តែសម្រាប់កែកំសាន្តនិងទទួលប្រាក់ចំណូលរួមពីការចិញ្ចឹមសត្វដែលគេពិនិត្យជាដំបូងគឺជា" ប្រាក់បន្តិចបន្តួច" ហើយវាអាចឈានដល់គម្រោងចិញ្ចឹមនោះរីកចម្រើន ឡើងទៅជាសហគ្រាសពានិជ្ជកម្ម។ ក្តីសង្ឃឹមប្រកបដោយសុទិដ្ឋិនិយមចំពោះប្រាក់ចំណូលផ្នែកសេដ្ឋកិច្ចខ្ពស់ពេក វាអាចនាំឲ្យអ្នកចិញ្ចឹមអនុវត្តន៍ខុសឆ្គងដោយសារការពង្រីកយ៉ាងឆាប់រហ័សពេក ហើយម្យ៉ាងទៀត ប្រសិនបើគេធ្វើគម្រោងនៃការចិញ្ចឹមដោយមិនបានប្រុងប្រយ័ត្ន។ ដំបូន្មានពិសេសគឺ " ឆ្នាំដំបូងត្រូវចាប់ផ្តើមពីតិច ហើយត្រូវពិនិត្យមើលថវិកា ថាតើអាចគ្រប់គ្រងលើអត្រាចំណាយរបស់អ្នកបាន ឬមិនបាន"។ ចូរធ្វើការកត់ត្រាដោយប្រុងប្រយ័ត្ននូវលទ្ធផលទាំងឡាយដែលមិនបានជោគជ័យលើផ្នែកហិរញ្ញវត្ថុដែលកើតឡើងដោយសារការប៉ុនប៉ងចាប់ផ្តើម

ការចិញ្ចឹមច្រើនដោយមិនដឹងពីប្រភព និងតម្លៃរបស់កូនមាន់ចំណីវិធីការពារជំងឺឬការលក់ដូរ។សៀវភៅនេះជួយធ្វើឲ្យអ្នកចិញ្ចឹមបក្សីដែលប្រើប្រាស់ដើមទុនតិចអាចពង្រីកការចិញ្ចឹមរបស់គេឲ្យទៅជាសហគ្រាសជំនួញមួយបានជោគជ័យ។ ការចិញ្ចឹមបក្សីដោយប្រើប្រាស់ដើមទុនច្រើន គឺជាឧស្សាហកម្ម កសិកម្មមានឯកទេសមួយដែលទាមទារនូវការសិក្សា។

# ជំពូកទី២
# ការចាប់ផ្តើមចិញ្ចឹម-ការជ្រើសរើសមាន់

( Getting started- securing stock )

មាន់គឺជាសត្វងាយស្រួលក្នុងការរកទិញ និងងាយស្រួលផ្លាស់ប្តូរទីកន្លែងហើយមានលក្ខណៈជ្រើសរើស៤វិធីសាស្ត្រផ្សេងៗគ្នាក្នុងការចាប់ផ្តើមចិញ្ចឹម។

**១-កូនមាន់អាយុ១ថ្ងៃ**( day-old baby chicks )

នេះគឺជាវិធីសាស្ត្រមួយយ៉ាងសាមញ្ញបំផុតនៃការចាប់ផ្តើមចិញ្ចឹម ឬការជ្រើសរើសពូជបក្សី។ **គុណសម្បត្តិ:** កូនមាន់អាយុ១ថ្ងៃ ត្រូវបានចិញ្ចឹមដោយខ្លួនឯងនូវសារធាតុអាហារជាតិក្រហមរបស់វាក្នុងរយៈពេល២ ឬ៣ថ្ងៃ ដូច្នេះវាមិនត្រូវការចំណី ឬទឹកក្នុងកំឡុងពេលដឹកជញ្ជូនយកទៅកន្លែងថ្មីនោះទេ។ **គុណវិបត្តិ:** ក្នុងរយៈពេលដឹកនាំកូនមាន់យកទៅកន្លែងថ្មីវាអាចមានគ្រោះថ្នាក់ខ្លះដែរជាការថប់ខ្យល់ដែលបណ្តាលមកពីធាតុអាកាសក្តៅពេក ឬត្រជាក់ពេក។ ថ្វីត្បិតតែកូនមាន់ត្រូវការកម្តៅច្រើនជាងមនុស្សក៏ដោយក៏កូនមាន់មួយក្រុមចំនួន២៥ក្បាលបង្កើតបាននូវកម្តៅគ្រប់គ្រាន់ និងមានសុវត្ថិភាពនៅក្នុងប្រអប់សម្រាប់ដឹកជញ្ជូន បើសិនជាប្រអប់នោះត្រូវបានចោះឲ្យមានរន្ធដើម្បីឲ្យមានខ្យល់ចេញចូលល្អហើយសីតុណ្ហភាពក្នុងបន្ទប់ត្រូវបានថែរក្សាជាមធ្យម។ ក្នុងការផ្តល់ចំណីអាហារនិងទឹកចាំបាច់ត្រូវតែផ្តល់បើសិនជាមានការដឹកកូមមាន់លើសពី២ ទៅ៣ថ្ងៃ។

**២-ការទិញស៊ុតយកមកភ្ញាស់**( purchase of hatching eggs )




គេត្រូវទិញពីកន្លែងបង្កាត់ពូជល្អៗ ហើយត្រូវរកមធ្យោបាយភ្ញាស់យ៉ាងណាឲ្យបានល្អប្រសើរ។ ម៉្យាងវិញទៀត ពងមាន់ដែលទិញមកត្រូវវេចខ្ចប់ឲ្យបានល្អពីព្រោះពងមាន់ងាយបែកជាទីបំផុត ជាតុអាកាសប្រែប្រួលមិនចោទជាបញ្ហា ដូចកូនមាន់ទេ។ ពងមាន់ដែលទិញបានហើយត្រូវយកមកភ្ញាស់ភ្លាមៗកុំទុករហូតដល់រយៈពេល១អាទិត្យឲ្យសោះ ទោះបីសីតុណ្ហភាពត្រូវបានថែរក្សា ១០អង្សាសេជាមធ្យមក៏ដោយ។